**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈទន្តពេទ្យកម្ពុជា**
**ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**
លេខ....០០២០/១៩.....កទជ

ថ្ងៃសុក្រ ៥កើត ខែជេស្ឋ ឆ្នាំកុរឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩

# សេចក្តីសម្រេច
## ស្តីពី
## លក្ខខណ្ឌនិងបែបបទនៃការស្នើសុំចុះបញ្ជិកា និងអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ

## ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៣៩៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥៦.អនក្រ.បកចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពី ក្រមសីលធម៌ទន្តពេទ្យ
- បានឃើញអនុក្រឹត្យលេខ ១៣៥៦.អនក្រ.តត ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ
- បានឃើញសេចក្តីសម្រេចលេខ០០១៩/១៥ កទជ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ស្តីពី បទបញ្ជាផ្ទៃក្នុងគណៈទន្តពេទ្យកម្ពុជា
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១.~**

ទន្តពេទ្យជាតិនិងទន្តពេទ្យបរទេសទាំងអស់ដែលមានបំណងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវស្នើសុំចុះបញ្ជិកា និងអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ នៅគណៈទន្តពេទ្យកម្ពុជា។


ឡូត៍លេខ D7 ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ៖012 799 001/076 649 6101,www.dentalcouncilofcambodia, Page; Dental Council of Cambodia

**ប្រការ ២.~**

ទន្តពេទ្យជាតិដែលស្នើសុំចុះបញ្ជិកាត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

ក.មានគុណវុឌ្ឍិក្នុងវិជ្ជាជីវៈរបស់ខ្លួនដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល

ខ.មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ

គ.មិនមានបញ្ហាសុខភាពផ្លូវកាយ ផ្លូវចិត្តដែលប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ។

**ប្រការ ៣.~**

អ្នកវិជ្ជាជីវៈទន្តសាស្ត្រជាតិ ដែលស្នើសុំអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

ក.បានបញ្ចប់ការសិក្សាយ៉ាងយូរពីរឆ្នាំ

ខ.បង្ហាញថាមានបច្ចុប្បន្នភាពបទពិសោធថ្មីៗ

គ.មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ

ឃ.មិនមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ

ង.មិនបានប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈទន្តសាស្ត្រ។

**ប្រការ ៤.~**

ទន្តពេទ្យបរទេស ដែលស្នើសុំចុះបញ្ជិកាត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

ក.មានគុណវុឌ្ឍិក្នុងវិជ្ជាជីវៈរបស់ខ្លួន ដែលទទួលស្គាល់ពីស្ថានទូតឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមី

ខ.មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ

គ.ជាសមាជិករបស់គណៈទន្តពេទ្យនៃប្រទេសសាមី មានសុពលភាព

ឃ.មានបទពិសោធវិជ្ជាជីវៈទន្តសាស្ត្រយ៉ាងតិច៥(ប្រាំឆ្នាំ)

**ប្រការ ៥.~**

អ្នកវិជ្ជាជីវៈទន្តសាស្ត្របរទេសដែលស្នើសុំបន្តអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រត្រូវបំពេញលក្ខខណ្ឌអប្បបរមា ដូចខាងក្រោម៖

ក.បង្ហាញថាមានបច្ចុប្បន្នភាពបទពិសោធថ្មីៗ

ខ.ជាសមាជិករបស់គណៈទន្តពេទ្យនៃប្រទេសសាមី មានសុពលភាព

គ.ជាសមាជិករបស់គណៈទន្តពេទ្យកម្ពុជា

ឃ.មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ

ង.មិនមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ

ច.គ្មានកំហុសឆ្គងវិជ្ជាជីវៈទន្តសាស្ត្រ ក្នុងប្រទេសសាមី ឬ/និងប្រទេសកម្ពុជា។



ឡូតិ៍លេខ D7 ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ៖012 799 001/076 649 6101,www.dentalcouncilofcambodia, Page; Dental Council of Cambodia

**ប្រការ ៦.~**

ទន្តពេទ្យបរទេស ដែលស្នើសុំចុះបញ្ជិការយៈពេលខ្លី (ចូលរួមសន្និសីទ សិក្ខាសាលា ការសិក្សាស្រាវជ្រាវ ។ល។ ដោយអនុវត្តផ្ទាល់ជាមួយអ្នកជំងឺ)ត្រូវបំពេញលក្ខខណ្ឌអប្បបរមា ដូចខាងក្រោម៖

ក.មានគុណវុឌ្ឍិក្នុងវិជ្ជាជីវៈរបស់ខ្លួន ដែលទទួលស្គាល់ពីស្ថានទូតឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមី

ខ.ជាសមាជិករបស់គណៈទន្តពេទ្យនៃប្រទេសសាមី មានសុពលភាព

គ.មានបទពិសោធវិជ្ជាជីវៈទន្តសាស្ត្រយ៉ាងតិច៥(ប្រាំឆ្នាំ)

**ប្រការ ៧.~**

បែបបទនៃការស្នើសុំចុះបញ្ជិកានៅគណៈទន្តពេទ្យកម្ពុជាទន្តពេទ្យជាតិត្រូវ៖

ក.មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនកម្ពុជា

ខ.មានសញ្ញាបត្រទន្តសាស្ត្រ ទទួលស្គាល់ពីក្រសួងសុខាភិបាល

គ.មានលិខិតថ្កោលទោសដែលចេញដោយក្រសួងយុត្តិធម៌ ឬកាតមន្ត្រីរាជការ

ឃ.មានការយល់ដឹងពីអនុក្រឹត្យក្រមសីលធម៌ទន្តពេទ្យនិងបទបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈទន្តសាស្ត្រ

ង.វិក័យបត្របង់ប្រាក់ស្នើសុំចុះបញ្ជិកា

ច.បំពេញបែបបទស្នើសុំចុះបញ្ជិកាតាមប្រព័ន្ធអ៊ិនធឺណែត www.hpc / RMS-ប្រព័ន្ធគ្រប់គ្រងអ្នកចុះបញ្ជិកា។

ការចុះបញ្ជិការបស់ទន្តពេទ្យកម្ពុជា មានសុពលភាពជាអចិន្ត្រៃយ៍ ជាអ្នកវិជ្ជាជីវៈទន្តសាស្ត្រ។

**ប្រការ ៨.~**

បែបបទនៃការស្នើសុំអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រអ្នកវិជ្ជាជីវៈទន្តសាស្ត្រជាតិត្រូវ៖

ក.មានលិខិតបញ្ជាក់សុខភាពផ្លូវកាយ និងផ្លូវចិត្តដែលចេញដោយរដ្ឋបាលនៃមន្ទីរពេទ្យរដ្ឋ

ខ.មានលិខិតថ្កោលទោសដែលចេញដោយក្រសួងយុត្តិធម៌ ឬកាតមន្ត្រីរាជការ

គ.មានលិខិតបញ្ជាក់ពីការបណ្តុះបណ្តាលបន្ត(CPD Points)

ឃ.មានការយល់ដឹងពីអនុក្រឹត្យក្រមសីលធម៌ទន្តពេទ្យនិងបទបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈទន្តសាស្ត្រ

ង.វិក័យបត្របង់ប្រាក់ភាគទានសមាជិក

ច.បំពេញបែបបទស្នើសុំអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រតាមប្រព័ន្ធអ៊ិនធឺណែត www.hpc / RMS-ប្រព័ន្ធគ្រប់គ្រងអ្នកចុះបញ្ជិកា។

រាល់ការស្នើសុំត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យត្រឹមត្រូវ និងគ្រប់គ្រាន់។

អាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ មានសុពលភាពរយៈពេល៣ឆ្នាំ និងអាចស្នើសុំបន្ត ដោយត្រូវបំពេញបែបបទ នៃការស្នើសុំអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ។



ឡូតិ៍លេខ D7 ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ៖012 799 001/076 649 6101,www.dentalcouncilofcambodia, Page; Dental Council of Cambodia

**ប្រការ ៩.~**

ការស្នើសុំបន្តអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រត្រូវធ្វើឡើង១៥(ដប់ប្រាំ)ថ្ងៃមុនសុពលភាពត្រូវបានបញ្ចប់។ ក្នុងករណីការស្នើសុំបន្តអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រធ្វើឡើងក្រោយសុពលភាពបានបញ្ចប់ ត្រូវទទួលរងការពិន័យដូចខាងក្រោមៈ

| | |
|---|---|
| ក.តិចជាង៣(បី)ខែ | ២០០,០០០.០០ (ពីរសែនរៀល) |
| ខ.តិចជាង៦(ប្រាំមួយ)ខែ | ៤០០,០០០.០០ (បួនសែនរៀល) |
| គ.លើស៦(ប្រាំមួយ)ខែ | ផ្អាកអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រជាបណ្ដោះអាសន្ន រយៈពេលមួយឆ្នាំ |
| ឃ.លើស១២(ដប់ពីរ)ខែ | ផ្អាកអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រជាបណ្ដោះអាសន្ន រយៈពេល២(ពីរ)ឆ្នាំ |
| ង.លើស២៤(ម្ភៃ)ខែ | បញ្ឈប់ពីសមាជិកភាពគណៈទន្តពេទ្យកម្ពុជា។ |

សុពលភាពនៃអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រដែលបានបន្ត ត្រូវគិតចាប់ពីថ្ងៃដែលសុពលភាព អាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រចាស់ត្រូវបានបញ្ចប់។

**ប្រការ ១០.~**

អ្នកវិជ្ជាជីវៈទន្តសាស្ត្រជាតិដែលបានបញ្ចប់ការសិក្សាផ្នែកទន្តសាស្ត្រលើសពី ពីរឆ្នាំ មិនទទួលបានអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រទេ លុះត្រាតែបំពេញលក្ខខណ្ឌ និងបែបបទដូចខាងក្រោមៈ

ក.បានអនុវត្តវិជ្ជាជីវៈទន្តសាស្ត្រ ជាមួយអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ដែលមានអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ រយៈពេលមួយឆ្នាំ

ខ.មានលិខិតបញ្ជាក់ពីការអនុវត្តការងារល្អ ក្រោយបញ្ចប់ការអនុវត្តវិជ្ជាជីវៈទន្តសាស្ត្រ។

**ប្រការ ១១.~**

បែបបទនៃការស្នើសុំចុះបញ្ជិកានៅគណៈទន្តពេទ្យកម្ពុជាទន្តពេទ្យបរទេសត្រូវៈ

ក.មានលិខិតឆ្លងដែន និងទិដ្ឋាការចេញចូលច្រើនដង (Visa multiple Entry)

ខ.មានសញ្ញាបត្រទន្តសាស្ត្រ បញ្ជាក់ដោយស្ថានទូត ឬអាជ្ញាធរមានសមត្ថកិច្ចប្រទេសសាមី

គ.មានអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ ដែលមានសុពលភាព

ឃ.លិខិតបញ្ជាក់ការអនុវត្តវិជ្ជាជីវៈល្អ (Good Standing Certificate) ដែលចេញដោយគណៈទន្តពេទ្យប្រទេសសាមី

ង.លិខិតថ្កោលទោស នៃប្រទេសសាមីនៅមានសុពលភាព

ច.មានលិខិតបញ្ជាក់ពីការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ដែលចេញដោយកន្លែងប្រកបវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជា

ឆ.មានការយល់ដឹងពីក្រមសីលធម៌និងបទបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈទន្តសាស្ត្រ



ឡូត៍លេខ D7 ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ៖012 799 001/076 649 6101,www.dentalcouncilofcambodia, Page; Dental Council of Cambodia

ជ.បំពេញបែបបទស្នើសុំចុះបញ្ជិកាសម្រាប់ទន្តពេទ្យបរទេសតាមប្រព័ន្ធអ៊ិនធឺណែត www.hpc / RMS-ប្រព័ន្ធគ្រប់គ្រងអ្នកចុះបញ្ជិកា។

រាល់ការស្នើសុំត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ក្នុងរយៈពេលមួយខែយ៉ាងយូរគិតចាប់ពីថ្ងៃទទួលពាក្យត្រឹមត្រូវ និងគ្រប់គ្រាន់។

ការចុះបញ្ជិកាដំបូង សម្រាប់ទន្តពេទ្យបរទេសមានតម្លៃជាអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ និងមានសុពលភាពរយៈពេលមួយឆ្នាំ។

**ប្រការ ១២.~**

បែបបទនៃការស្នើសុំបន្តអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រនៅគណៈទន្តពេទ្យកម្ពុជាអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្របរទេសត្រូវ៖

ក.មានលិខិតឆ្លងដែន និងទិដ្ឋាការចេញចូលច្រើនដង (Visa multiple Entry)

ខ.មានអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ ដែលមានសុពលភាព

គ.លិខិតថ្កោលទោស នៃប្រទេសសាមី ឬប្រទេសកម្ពុជា ដែលមានសុពលភាព

ឃ.មានលិខិតបញ្ជាក់ពីការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ដែលចេញដោយកន្លែងប្រកបវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជា

ង.មានការយល់ដឹងពីក្រមសីលធម៌និងបទបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈទន្តសាស្ត្រ

ច.មានលិខិតបញ្ជាក់ពីការបណ្តុះបណ្តាលបន្ត (CPD Points)

ឆ.គ្មានកំហុសឆ្គងវិជ្ជាជីវៈទន្តសាស្ត្រ ក្នុងប្រទេសសាមី ឬ/និងប្រទេសកម្ពុជា

ជ.បំពេញបែបបទស្នើសុំបន្តអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រសម្រាប់ទន្តពេទ្យបរទេសតាមប្រព័ន្ធអ៊ិនធឺណែត www.hpc / RMS-ប្រព័ន្ធគ្រប់គ្រងអ្នកចុះបញ្ជិកា។

រាល់ការស្នើសុំត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ក្នុងរយៈពេលមួយខែយ៉ាងយូរគិតចាប់ពីថ្ងៃទទួលពាក្យត្រឹមត្រូវ និងពេញលេញ។

អាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រសម្រាប់ទន្តពេទ្យបរទេស មានសុពលភាពរយៈពេលមួយឆ្នាំនិងអាចស្នើសុំបន្ត។

**ប្រការ ១៣.~**

ការស្នើសុំបន្តអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រសម្រាប់ទន្តពេទ្យបរទេស ត្រូវធ្វើឡើង១៥(ដប់ប្រាំ)ថ្ងៃមុនសុពលភាពត្រូវបានបញ្ចប់។ ក្នុងករណីការស្នើសុំបន្តអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ ធ្វើឡើងក្រោយសុពលភាពបានបញ្ចប់ ត្រូវទទួលរងការពិន័យដូចខាងក្រោម៖

ក.តិចជាង២(ពីរ)ខែ ៤០០,០០០.០០ (បួនរយពាន់)រៀល

ខ.តិចជាង៤(បួន)ខែ ៨០០,០០០.០០ (ប្រាំបីរយពាន់)រៀល

គ.លើស៤(បួន)ខែ ត្រូវស្នើសុំចុះបញ្ជិកាជាថ្មី។



ឡូត៍លេខ D7 ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ៖012 799 001/076 649 6101,www.dentalcouncilofcambodia, Page; Dental Council of Cambodia

សុពលភាពនៃអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រដែលបានបន្ត ត្រូវគិតចាប់ពីថ្ងៃដែលសុពលភាព អាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រចាស់ត្រូវបានបញ្ចប់។

**ប្រការ ១៤.~**

បែបបទនៃការស្នើសុំចុះបញ្ជិការយៈពេលខ្លីនៅគណៈទន្តពេទ្យកម្ពុជាទន្តពេទ្យបរទេសត្រូវមានៈ

ក.ច្បាប់ចម្លងលិខិតឆ្លងដែន

ខ.ច្បាប់ចម្លងសញ្ញាប័ត្រទន្តសាស្ត្រ បញ្ជាក់ដោយស្ថានទូត ឬអាជ្ញាធម៌មានសមត្ថកិច្ចប្រទេសសាមី

គ.ច្បាប់ចម្លងអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ ដែលមានសុពលភាព

ឃ.លិខិតស្នើសុំពីប្រធានស្ថាប័ន ឬពីទន្តពេទ្យជាតិដែលមានអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ។

រាល់ការស្នើសុំត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ក្នុងរយៈពេល១០(ដប់)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់។

**ប្រការ ១៥.~**

ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ រាជធានី ខេត្ត មានតួនាទីអនុវត្តសេចក្តីសម្រេចនេះ។

**ប្រការ ១៦.~**

សេចក្តីសម្រេចលេខ០០២៣/១៥ ក.ទ.ជ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពី លក្ខខណ្ឌ និងបែបបទនៃការចុះបញ្ជី ត្រូវបានចាត់ទុកជានិរាករណ៍។

**ប្រការ ១៧.~**

សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ. ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**
**ប្រធាន**

DENTAL COUNCIL OF CAMBODIA

**ទន្តបណ្ឌិត.សុខុម រិទ្ធីវុធ**

**កន្លែងទទួលៈ**
- ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ
- ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ
- ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ



ឡូតិ៍លេខ D7 ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទៈ012 799 001/076 649 6101,www.dentalcouncilofcambodia, Page; Dental Council of Cambodia